0028331 A190/II/9

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

***តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១២)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២០ កុម្ភៈ ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 02 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.-Try

---

សាធារណៈ:

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ**

---

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**<u>ជនត្រូវចោទ</u>**

អៀង សារី

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE

**<u>សហមេធាវីការពារក្តី</u>**

អាង ឧត្តម
Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.-Try

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00283312





**អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** "អ.វ.ត.ក" បានទទួលបណ្តឹង "បណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចរបស់[ការិយាល័យសហចៅក្រមស៊ើបអង្កេត] ស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

## ជំពូក ១ - សេចក្តី

១. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ("ដីកាស្តីពីការបកប្រែ")។ ដីកានេះ បានជូនដំណឹងដល់ភាគីទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដោយរួមទាំងជនត្រូវចោទផងដែរ[1]។

២. នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ចំពោះដីកាស្តីពីការបកប្រែ និងសារណាបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី២២ ខែកក្កដា។

៣. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ពាក្យសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់ចម្លើយតបរបស់ខ្លួន។ ក្រោយពីទទួលបានសេចក្តីសន្និដ្ឋានតបរបស់ជនត្រូវចោទ អង្គបុរេជំនុំជម្រះបានទទួលយកពាក្យសុំនេះ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៨ ហើយបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរបស់ខ្លួន ត្រឹមថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ ។

៤. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយរបស់ខ្លួនតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

៥. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

---

[1] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ A190 ("ដីកាស្តីពីការបកប្រែ")។

៦. អង្គបុរេជំនុំជម្រះ បានទទួលសំណើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ សំណើនេះត្រូវបានអង្គបុរេជំនុំជម្រះបដិសេធចោល។[២]

៧. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះ តាមសំណើរបស់ភាគី បានសម្រេចធ្វើការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ហើយអនុញ្ញាតឱ្យសហមេធាវីការពារក្តីធ្វើការដាក់សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា។[៣]

៨. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ក្រុមមេធាវីការពារក្តីបានដាក់សារណាតបរបស់ខ្លួន ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ("ចម្លើយតប")។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៩. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចស្តីពីការបកប្រែ ហើយបានជូនដំណឹងដល់ភាគីទាំងឡាយ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨។ សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ដោយអនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង។ សារណាបណ្តឹងឧទ្ធរណ៍ បានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ហេតុដូច្នេះហើយ សារណាបណ្តឹងឧទ្ធរណ៍នេះ បានដាក់ទាន់កាលបរិច្ឆេទកំណត់។

---

[២] សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ A190/II/6។

[៣] សេចក្តីសម្រេចអំពីការកំណត់លើបណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ A190/II/7។

00283314



## ក. សេចក្តីសន្និដ្ឋានរបស់ភាគី

១០. សហមេធាវីការពារក្តីជនត្រូវចោទ សន្និដ្ឋានថា "សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ចុះថ្ងៃទី១០ ខែមករា[៤] និងលិខិតរំលឹកដល់សហចៅក្រមស៊ើបអង្កេតអំពីសំណើចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨[៥] បានបង្កើតជាសំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០)។ ដូច្នេះ ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាស្តីពីការបកប្រែ បានបង្កើតជាដីកាបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលអនុញ្ញាតតាមវិធានផ្ទៃក្នុង ហើយបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។[៦] ដោយទទួលស្គាល់ថា "មិនមាននិយមន័យអ្វីច្បាស់លាស់ចំពោះអ្វីដែលកំណត់បានថាជាការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ក្រោមវិធានផ្ទៃក្នុង ៥៥(១)" សហចៅក្រមស៊ើបអង្កេតលើកឡើងថា "អត្ថន័យដ៏សមហេតុផលចំពោះកិច្ចស៊ើបសួរ គឺថាវាជាកិច្ចមួយដែលមានផលប៉ះពាល់ដល់ខ្លឹមសារនៃកិច្ចស៊ើបសួរ" ហើយ "នេះមានន័យយ៉ាងជាក់លាក់ថា ជាកិច្ចអ្វីមួយដែលទាក់ទងដល់ការប្រមូលភស្តុតាងដែលនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដែលជាប់ទាក់ទិនដល់ភាពមានពិរុទ្ធ ឬ ភាពគ្មានកំហុស"។[៧] នៅក្នុងការយល់ឃើញរបស់សហមេធាវីការពារក្តី "ការបដិសេធដោយ ក.ស.ច.ស មិនបង្គាប់ឱ្យបកប្រែនូវឯកសារចោទប្រកាន់គាំទ្រនូវពិរុទ្ធភាពរបស់លោក **អៀង សារី** បង្កើតបានជាការបដិសេធមិនបំពេញកិច្ចមួយ ដែលអាចនឹងត្រូវបន្ថែមភស្តុតាងទៅក្នុងសំណុំរឿង។"[៨]

១១. សហមេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថា "ដីកាសម្រេចស្តីពីការបកប្រែនេះ រំលោភលើសិទ្ធិរបស់ លោក **អៀង សារី** ដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់ខ្លួន ដែលមានផ្លូវតែ

---

[៤] សំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ A120។

[៥] លិខិតរបស់ក្រុមការពារក្តីលោក អៀង សារី ដាក់ជូនសហចៅក្រមស៊ើបអង្កេត ស្តីពី "កង្វះការឆ្លើយតបទៅនឹងសំណើសុំពន្លឿនការបកប្រែរាល់ឯកសារចំណុះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅជាភាសាខ្មែរ និងអង់គ្លេស" ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៨ A120/I។

[៦] បណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ A190/II/1 ("សារណាបណ្តឹងឧទ្ធរណ៍") វាក្យខណ្ឌទី ១។

[៧] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៣។

[៨] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៤។

00283315

A190/II/9



មួយគត់ដែលសិទ្ធិអាចនឹងត្រូវបានការពារ បើសិនជាគាត់មានលទ្ធភាពពិនិត្យមើលភស្តុតាងដែលបញ្ចូលមកប្រឆាំងនឹងគាត់ ជាភាសាដែលគាត់អាចយល់បានទាំងស្រុងនោះគឺជាភាសាខ្មែរ។ ដីកាសម្រេចនេះ ក៏រំលោភបំពានផងដែរនូវសិទ្ធិជាមូលដ្ឋានរបស់លោក **អៀង សារី** ក្នុងការទទួលបានការតំណាងក្តីដោយមានប្រសិទ្ធិភាព ដែលរារាំងមេធាវីបរទេសរបស់គាត់មិនឱ្យមានលទ្ធភាពពិនិត្យ និងវិភាគភស្តុតាងប្រឆាំងនឹងកូនក្តីរបស់ខ្លួន ជាភាសាដែលមេធាវីនោះយល់ដឹងបាន គឺ ភាសាអង់គ្លេស។"[៩] នៅក្នុងការយល់ឃើញ របស់សហមេធាវីការពារក្តី ដីកាសម្រេចស្តីពីការបកប្រែ ក៏បានរំលោភលើគោលការណ៍សមភាពនៃគូរភាគីក្តី ពីព្រោះដីកានេះបានបង្វែរបន្ទុកបកប្រែពីតុលាការ មកដាក់លើផ្នែកគាំពារការពារក្តីវិញ។[១០]

១២. សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ ពីព្រោះ៖ "សេចក្តីសម្រេចទាក់ទងនឹងការបកប្រែនេះ មិនមែនជាសេចក្តីសម្រេចមួយ ក្នុងចំណោមសេចក្តីសម្រេចនានា ដែលបើកផ្លូវឱ្យជនត្រូវចោទប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាននោះទេ។ ម្យ៉ាងវិញទៀត បណ្តឹងឧទ្ធរណ៍នេះ ក៏មិនគួរនឹងទទួលយកដែរ ព្រោះថា៖ ទី១) ច្បាប់កំពុងអនុវត្ត និងបទដ្ឋានអន្តរជាតិ តម្រូវឱ្យមានការបកប្រែឯកសារជាក់លាក់មួយចំនួនតែប៉ុណ្ណោះ (មិនមែនឯកសារទាំងអស់នោះទេ) ឱ្យទៅជាភាសាមួយដែលចុងចោទយល់បាន, ទី២) ចុងចោទមិនមានសិទ្ធិឱ្យគេបកប្រែគ្រប់ឯកសារទាំងអស់ ឱ្យទៅជាភាសារបស់ក្រុមមេធាវីអន្តរជាតិរបស់ខ្លួននោះទេ ជាពិសេស នៅពេលដែលក្រុមការពារក្តី និងផ្នែកគាំពារការការពារក្តីមានសមត្ថភាពផ្នែកភាសាវិទ្យាគ្រប់គ្រាន់រួចទៅហើយនោះ, ទី៣) ការផ្តល់អ្នកបកប្រែដោយមិនគិតកម្រៃ បន្ថែមឱ្យទៅខាងក្រុមមេធាវីការពារក្តី មិនបានបដិសេធសមភាពគូរភាគីក្តីឡើយ ក៏ប៉ុន្តែ វាបានផ្តល់ជំនួយបន្ថែមលើសមត្ថភាពផ្នែកភាសាវិទ្យារបស់ខ្លួនទៅវិញទេ។"[១១]

---

[៩] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៧។

[១០] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៨។

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ A190/II/5 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") វាក្យខណ្ឌទី ៣។

00283316

A190/II/9



## ខ. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ

១៣. វិធាន ៧៣ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ៧៣: យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ**

បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្ដីលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្ដីអំពីការបង្កើតអង្គជំនុំ ជម្រះវិសាមញ្ញ មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលត្រូវមានសមត្ថកិច្ច ដើម្បីពិនិត្យលើ ៖

ក- បណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្ដីសម្រេច និង កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤ ។

ខ- ពាក្យសុំមោឃៈភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦ និង

គ- បណ្ដឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១-៥ និង ១១-៦ វិធាន ២៣-៧ និង ២៣-៨ វិធាន ៣៥-៦ និង វិធាន ៣៨-៣ នៃ[វិធានផ្ទៃក្នុងនេះ]។

១៤. នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ វិធាន ៧៤ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ៧៤: មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ**

១. គ្មានបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបានឡើយ ប្រសិនបើបណ្ដឹងនេះត្រូវបានពិនិត្យ និង សម្រេចរួចហើយ ដោយអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមការដោះស្រាយភាពខ្វែងយោបល់គ្នាដែលមានចែងនៅក្នុងវិធាន ៧២។

២. សហព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។

៣. ជនត្រូវចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖

ក- ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ខ- ការបដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

00283317

A190/II/9



គ- ការបដិសេធពាក្យសុំឱ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក។

ឃ- ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ង- ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ។

ច- ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ។

ឆ- ការបដិសេធពាក្យសុំឱ្យប្ដឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃៈភាពកិច្ចស៊ើបសួរណាមួយ។ ឬ

ជ- ទាក់ទងទៅនឹងវិធានការការពារ។"

១៥. ដោយសារបណ្ដឹងឧទ្ធរណ៍នេះយកវិធាន ៧៤(៣)(ខ) មកធ្វើជាមូលដ្ឋានសម្អាង, ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ វិធានផ្ទៃក្នុងបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ដែលសម្រេចបដិសេធ[សំណើ]សុំបំពេញកិច្ចស៊ើបសួរ" បែបនេះដែរឬទេ។

**សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលដាក់ជូនដោយជនត្រូវចោទ**

១៦. វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ផ្ដល់សិទ្ធិឱ្យជនត្រូវចោទស្នើសុំបំពេញកិច្ចស៊ើបសួរ៖

> " នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា បដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។"

១៧. វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងចែងបន្តទៀតថា៖

> " ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្តុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយល័ក្ខអក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាម ដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទ ត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិសេធនេះ។ ជនត្រូវចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ។"

១៨. វិធានផ្ទៃក្នុងមិនបានកំណត់អត្ថន័យនៃពាក្យ"កិច្ចស៊ើបសួរ"ឱ្យបានច្បាស់លាស់។ ប៉ុន្តែ អត្ថន័យនៃពាក្យនេះ អាចធ្វើការសន្និដ្ឋានយល់បាន នៅពេលយើងអានបទប្បញ្ញត្តិផ្សេងៗ នៃវិធានផ្ទៃក្នុងរួមគ្នា។

១៩. ក្នុងករណីនេះ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងចែងថា៖

> " ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាច<u>ចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់</u>។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ។ [...]" (គូសបញ្ជាក់បន្ថែម)

២០. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ដំណើរការលាតត្រដាងការពិត ចាំបាច់ត្រូវពាក់ព័ន្ធនឹងការប្រមូលព័ត៌មាន។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការប្រមូលភស្តុតាងជាការពិតណាស់ គឺជាគោលបំណងនៃកិច្ចស៊ើបសួរ។[១២] នៅក្នុងប្រព័ន្ធច្បាប់បារាំង កិច្ចស៊ើបសួរ គឺជាកិច្ចទាំងឡាយ

[១២] Pierre Chambon and Christian Guéry, *Droit et pratique de l'instruction préparatoire*, Dalloz: 2008, p. 6.

ណា ដែលចៅក្រមស៊ើបអង្កេតបានធ្វើឡើងដើម្បីស្វែងរកភស្តុតាង។[១៣] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រព័ន្ធច្បាប់ព្រះរាជាណាចក្រកម្ពុជា ដែលវិធានផ្ទៃក្នុងយកមកធ្វើជាមូលដ្ឋានសម្អាងនោះ គឺវាស្រដៀងនឹងប្រព័ន្ធច្បាប់បារាំង។

២១. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធាន៥៨(៦) នៃវិធានផ្ទៃក្នុង រៀបរាប់ជាក់លាក់អំពីសំណើទាំងឡាយ ដែលជនត្រូវចោទអាចស្នើទៅសហចៅក្រមស៊ើបអង្កេត។ វិធាននេះ សំដៅលើតែកិច្ចទាំងឡាយណា ដែលធ្វើឡើងដើម្បីជាគោលបំណងនៃការប្រមូលភស្តុតាងតែប៉ុណ្ណោះ។

២២. ការចង្អុលបង្ហាញមួយទៀតដែលកិច្ចស៊ើបសួរធ្វើឡើងដើម្បីប្រមូលភស្តុតាង អាចកត់សម្គាល់ឃើញនៅក្នុងវិធាន ៦២ នៃវិធានផ្ទៃក្នុង។ វិធាននេះ ចែងអំពីលទ្ធភាពដែលសហចៅក្រមស៊ើបអង្កេត អាចធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក. ឬ មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។ នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ, វិធាន ៦២ នៃវិធានផ្ទៃក្នុង ចែងថា៖

> " ១. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមានអំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ។
>
> ២. ដីកាចាត់ឱ្យស៊ើបសួរជំនួស មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ តែត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ និងដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬជាមួយនឹងបទល្មើសដែលកំពុងស៊ើបសួរ។ [...]
>
> ៣. អ្នកទទួលការចាត់តាំងត្រូវធ្វើការងារក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវរាយការណ៍ជូនទៅសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ អំពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ នៅពេលដែលដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឱ្យទៅអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬ នគរបាលយុត្តិធម៌ ជននោះត្រូវអនុវត្តដូចខាងក្រោម:
>
> ក- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន ដោយអនុលោម

---

[១៣] Jean Pradel, *Manuel de Procédure Pénale*, Cujas: 2000, para. 723: "Positivement, les actes d'instruction sont tous les actes de recherche des preuves accomplis par le juge d'instruction et tous ceux qui ont été accomplis au cours de l'enquête de police en ce qu'ils font partie de la procédure d'instruction."

តាមបញ្ញត្តិនៃវិធាន ៥១-៨ តាមករណីសមស្រប។

ខ- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតមិនត្រូវសួរចម្លើយជនត្រូវចោទឡើយ។ អ្នកស៊ើបអង្កេតអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមអនុវិធាន ៥៩(៦)។

គ- នគរបាលយុត្តិធម៌ អាចឆែកឆេរ និងចាប់យកភស្តុតាងបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។

[...]"

២៣. ផ្អែកលើសេចក្តីពិចារណាទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំបំពេញកិច្ចស៊ើបសួរ គួរត្រូវគេបកស្រាយថា ជាសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬ អ្នកស៊ើបអង្កេត ឬក៏មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឱ្យសួរជំនួស បំពេញកិច្ចណាមួយ ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត។

## ដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ

២៤. ដីកាសម្រេចស្តីពីការបកប្រែ កំណត់សិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ។ ពាក់ព័ន្ធនឹងដីកានេះ សហចៅក្រមស៊ើបអង្កេត បានលើកឡើងថា៖

> " យល់ឃើញពីភាពខ្វះចន្លោះនៃបទប្បញ្ញត្តិ ស្តីពីវិសាលភាពនៃសិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធនឹងការបកប្រែ
>
> យល់ឃើញថា ខ្លឹមសារនៃសិទ្ធិ និងកាតព្វកិច្ចនេះ គឺជាបញ្ហាសំខាន់ដែលទាក់ទងទៅនឹងផលប្រយោជន៍ទូទៅ ដូច្នេះសហចៅក្រមស៊ើបអង្កេត បានសម្រេចចេញអនុស្សារណៈនេះទៅគ្រប់ភាគីទាំងអស់ [...]"[១៤]

២៥. ដីកាសម្រេចស្តីពីការបកប្រែ ពុំបង្កើតជាកិច្ចមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានឡើយ។ បន្ថែមពីនេះទៀត គេកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិន

[១៤] ដីកាស្តីពីការបកប្រែ ទំព័រទី ២។

00283321



ទទួលបានសំណើសុំឱ្យបំពេញកិច្ចណាមួយ ដែលជាលក្ខខណ្ឌមួយនៃការបំពេញកិច្ចស៊ើបសួរ ដូចដែលបានលើកឡើងខាងលើនោះទេ។

២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះ មិនបានប្ដឹងប្រឆាំងចំពោះដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ។ ដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះ មិនស្ថិតនៅក្នុងរង្វង់នៃកម្មវត្ថុនានា ដែលបើកផ្លូវឱ្យប្ដឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង ឡើយ។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា មិនមានបទប្បញ្ញត្តិណាផ្សេងជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង ដែលបើកផ្លូវឱ្យជនត្រូវចោទប្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាស្ដីពីការបកប្រែ នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។

២៨. វិធានផ្ទៃក្នុងចែងអំពីដីកាមួយចំនួន ដែលបើកផ្លូវឱ្យជនត្រូវចោទប្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដីកាទាំងនេះ មានចែងគ្រប់ទាំងអស់ ហើយអង្គបុរេជំនុំជម្រះមានយុត្តាធិការសម្រេចលើបណ្ដឹងឧទ្ធរណ៍ចំពោះដីកា និងសេចក្ដីសម្រេចទាំងឡាយណា ដែលបានលើកឡើងនៅក្នុងនោះតែប៉ុណ្ណោះ។ ដីកាសម្រេចដទៃទៀតរបស់សហចៅក្រមស៊ើបអង្កេត ស្ថិតនៅក្រោមការត្រួតពិនិត្យ តាមរយៈនីតិវិធីមោឃភាព ដែលនីតិវិធីនេះអនុញ្ញាតឱ្យជនត្រូវចោទស្នើសុំឱ្យតុលាការ មោឃៈនីតិវិធីណាមួយដែលមានវិការៈ ជាហេតុនាំឱ្យមានការរំលោភលើសិទ្ធិរបស់ខ្លួន។[១៥] អង្គបុរេជំនុំជម្រះសង្កេតឃើញថា នីតិវិធីនេះគឺខុសពីនីតិវិធីនៃការប្ដឹងឧទ្ធរណ៍។ ដូច្នេះ សហមេធាវីការពារក្ដីត្រូវមានចំណាត់ការផ្សេងគ្នា ក្នុងការលើកយកបញ្ហាមកចំពោះមុខអង្គបុរេជំនុំជម្រះ។

---

[១៥] វិធាន ៧៦(៤) *ទឡ្ហីករណ៍* និងវិធាន ៤៨ នៃវិធានផ្ទៃក្នុង។



ECCC * CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

២៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីធ្វើការចោទប្រកាន់ថា ដីកាសម្រេចស្តីពីការបកប្រែ បានរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដូចបានពន្យល់នៅក្នុងវាក្យខណ្ឌទី ១១ ខាងលើ។

៣០. ចំពោះករណីនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា៖

> **"វិធាន ២១: គោលការណ៍ជាសារវ័ន្ត**
>
> ១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖
>
> ក- ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...]
>
> [...]
>
> ឃ- ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។"

៣១. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យថាតើវិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឱ្យធ្វើការបកស្រាយសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ក្នុងន័យទូលាយដែរឬទេ ដើម្បីធានាថា ដំណើរការ

នីតិវិធីក្នុងពេលស៊ើបសួរ មានភាពយុត្តិធម៌ និងបានគោរពគោលការណ៍ចំពោះមុខ ហើយបានរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

៣២. ដីកាសម្រេចស្តីពីការបកប្រែចែងថា ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែនូវឯកសារដូចខាងក្រោម ជាភាសាខ្មែរ និងភាសាអង់គ្លេស ៖

- ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត
- ភស្តុតាង ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងយកមកធ្វើជាមូលដ្ឋានសម្អាង
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា
- លេខយោង និងតារាងអក្សររៀងនៃអង្គហេតុ ដែលដីកាទាំងនេះសម្អាងលើ (ជាក់ស្តែងគឺឯកសារ D3 និង D3/I-V)
- សេចក្តីសម្រេច និងដីកាទាំងអស់របស់តុលាការ និង
- ឯកសារទាំងអស់ដែលភាគីបានដាក់ជូនទៅចំពោះមុខ អ.វ.ត.ក. ដូចមានចែងនៅក្នុងមាត្រា ៧(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក។[១៦]

៣៣. សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា ដីកាសម្រេចនេះ បានធ្វើឡើងក្នុងគោលបំណងកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ក្នុងអំឡុងកិច្ចស៊ើបសួរ និង "ក្នុងគោលបំណងឱ្យអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលទទួលបានសំណុំរឿង រៀបចំចាត់ចែងលើសេចក្តីត្រូវការនៃការបកប្រែសម្រាប់សវនាការនានា ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងល្អរបស់តុលាការ និងសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌។[១៧]

៣៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អនុលោមតាមវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទ មានសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទដាក់បន្ទុកមកលើខ្លួន។ ប៉ុន្តែ ទាំងច្បាប់

---

[១៦] សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅអវតក, អវតក/០១/២០០៧ វិ. លើកទី៣។

[១៧] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ង (៤)។

អ.វ.ត.ក. ទាំងវិធានផ្ទៃក្នុង ពុំផ្តល់សិទ្ធិជាក់លាក់បែបនេះដល់ជនត្រូវចោទ ក្នុងការទទួលបាន ការបកប្រែឯកសារទាំងអស់នៅក្នុងសំណុំរឿង ទៅជាភាសារបស់ជនត្រូវចោទ ឬជាភាសា របស់មេធាវីការពារក្តីខ្លួនឡើយ។ ទោះបីជាភាសានោះ ជាភាសាផ្លូវការមួយក្នុងចំណោម ភាសាផ្លូវការទាំងបីរបស់តុលាការ, វាក៏ពុំបង្កើតជាសិទ្ធិឲ្យជនត្រូវចោទ ក្នុងការទទួលបានការ បកប្រែឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងរបស់ខ្លួន ទៅជាភាសានោះឡើយ។

៣៥. ស្របជាមួយសម្អាងហេតុនៅក្នុងដីកាស្តីពីការបកប្រែ[១៨] យុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិ នានា សម្រេចដដែលៗថា សិទ្ធិរបស់ចុងចោទក្នុងការទទួលបានការបកប្រែឯកសារទៅជា ភាសាដែលខ្លួនយល់ ពុំរួមបញ្ចូលគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ខ្លួនឡើយ[១៩] ទោះបីជាក្នុងករណីចុងចោទធ្វើជាតំណាងដោយខ្លួនឯងក៏ដោយ។[២០] ហើយសំណើសុំការបក ប្រែសំណុំរឿងទាំងអស់ទៅជាភាសាមេធាវីរបស់ចុងចោទនោះទៀតសោត ក៏ត្រូវបានសាលា ក្តីបដិសេធចោលដែរ។[២១] ពិសេសជាងនេះទៅទៀត សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី និង សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា, សាលាក្តីទាំង ពីរនេះ បានលើកចោលសំណើសុំបកប្រែឯកសារទាំងអស់ ដោយផ្អែកលើមូលដ្ឋានថា ការបក ប្រែជាមុននូវរាល់ និងគ្រប់ឯកសារទាំងអស់ជាភាសារបស់ជនជាប់ចោទ លើសពីលក្ខខណ្ឌ តម្រូវដែលមានចែងនៅក្នុងលក្ខន្តិកៈ និងវិធាននានា, អាចប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជន ជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្នុងពេលមួយឆាប់រហ័ស ពីព្រោះបញ្ហាពេលវេលា និងធនធាន ដែលទាមទារនៅក្នុងការបកប្រែឯកសារទាំងអស់ មានទំហំធំធេងណាស់។”[២២]

---

[១៨] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ក (៣) និង ខ (២)។

[១៩] *Prosecutor v. Lubanga*, ICC-01/04-01/06, "Decision on the Requests of the Defence of 3 and 4 July 2006", Pre-Trial Chamber I, 4 August 2006 ("*Lubanga*"), pp. 5-6; *Prosecutor v. Katanga*, ICC-01/04-01/07, "Decision on Defence for Mathieu Ngudjolo Chui's Request Concerning Translation of Documents", Pre-Trial Chamber I, 15 May 2008, pp. 3 and 5; *Prosecutor v. Chui*, ICC-01/04-02/07, "Decision on the Defense Request Concerning Time Limits", Pre-Trial Chamber I, 27 February 2008, pp. 3-4; *Prosecutor v. Muhimana*, ICTR-95-I-B-I, "Decision on Defence Motion for the Translation of Prosecution and Procedural Documents into Kinyarwanda", Trial Chamber I, 6 November 2001 ("*Muhimana*"), para. 25; *Prosecutor v. Seselj*, IT-03-67-PT, "Order on Translation", Trial Chamber II, 6 March 2003 ("*Seselj*"), p. 1; Prosecutor v. Ljubicic, IT-00-41-PT, "Decision on Defence Counsel's Request for Translation of All Documents", Trial Chamber I, 20 November 2002 ("*Ljubicic*"), p. 3; *Prosecutor v. Naletilic*, IT-98-34-T, "Decision on Defence's Motion Concerning Translation of All Documents", Trial Chamber I, 18 October 2001, p. 3; *Prosecutor v. Delalic*, IT-96-21-T, "Decision on Defence Application for Forwarding the Documents in the Language of the Accused", Trial Chamber, 25 September 1996, para. 8; *Kamasinski v. Austria*, Application No. 9783/82, 19 December 1989 ("*Kamasinski*"), para. 74.

[២០] See *Seselj*.

[២១] *Muhimana*, paras 31-33.

[២២] *Ljubicic*, p. 3; See also *Seselj*, p. 2; *Muhimana*, para. 12.

តុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចថា គោលការណ៍យុត្តិធម៌ពុំបាន "ផ្តល់ដល់ [ជនត្រូវចោទ] នូវសិទ្ធិទទួលបានការបកប្រែឯកសារទាំងអស់ដែលទាក់ទងនឹងបញ្ហានីតិវិធី និងឯកសារភស្តុតាងទាំងអស់ ដែលបង្ហាញជូនដោយអយ្យការឡើយ។"[២៣]

៣៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ផ្អែកតាមកាលៈទេសៈជាក់លាក់នៃរឿងក្តី ការបកប្រែឯកសារណាមួយ(នានា) អាចជាភាពចាំបាច់ក្នុងការធានាឱ្យជនត្រូវចោទមានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងកិច្ចស៊ើបសួរ។[២៤] ការសម្រេចថា "លក្ខខណ្ឌសំខាន់គឺ ដើម្បីអនុញ្ញាតឱ្យជនត្រូវចោទមាន "ការយល់ដឹងពីសំណុំរឿងដែលដាក់បន្ទុកខ្លួន និងអាចការពារខ្លួនឯងបាន ជាពិសេសអាចបកស្រាយអំពីអង្គហេតុជូនតុលាការបាន""[២៥], សហចៅក្រមស៊ើបអង្កេតបានកំណត់បទដ្ឋានមួយដែលត្រូវធានាថា ជនត្រូវចោទអាចអនុវត្តសិទ្ធិនានារបស់ខ្លួន ក្នុងអំឡុងកិច្ចស៊ើបសួរ និងដើម្បីធានាគោលការណ៍យុត្តិធម៌ នៃកិច្ចដំណើរការនីតិវិធីនៅក្នុងដំណាក់ការនេះ។

៣៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមអំណាចនៃដីកាស្តីពីការបកប្រែ ជនត្រូវចោទបានទទួលឯកសារដូចខាងក្រោមនេះ ជាភាសាខ្មែរ និងភាសាអង់គ្លេស៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ដោយរួមបញ្ចូលទាំងលេខយោង ដែលរៀបរាប់ឯកសារគាំទ្រការចោទប្រកាន់របស់សហព្រះរាជអាជ្ញា

---

[២៣] *Lubanga*, p. 6. តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សបានសម្រេចថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានរំលោភដោយសារតែករណីដែលឯកសារទាំងអស់មិនមានជាភាសាដែលខ្លួនយល់នោះទេ: *Kamasinski.*

[២៤] តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សបានសម្រេចដោយស្របគ្នាថា វិធីសាស្ត្រដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគេយកមកអនុវត្តនៅក្នុងពេលស៊ើបអង្កេតបឋម "អាស្រ័យលើលក្ខណៈពិសេសនៃដំណើរការក្តីដែលពាក់ព័ន្ធ និងកាលៈទេសៈនៃរឿងក្តី" ហើយ"ដើម្បីសម្រេចថា គោលបំណងនៃមាត្រា ៦ - ការជំនុំជម្រះដោយយុត្តិធម៌ - ទទួលបាន ដែរឬទេ, ដំណើរការក្តីក្រោមច្បាប់ជាតិទាំងមូលដែលគេធ្វើឡើងនៅក្នុងរឿងក្តីត្រូវយកមកពិចារណា"។ See in particular *Imbroscia v. Switzerland,* Application no. 13972/88, 24 November 1993, para. 38. See also *Granger v. the United Kingdom*, Application no. 11932/86, 28 March 1990, para. 44.

[២៥] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ខ(២)។ នេះក៏ជាបទដ្ឋានផងដែរ ដែលអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និង តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្ស។ See in particular *Lubanga*, p. 5 quoting para. 74 of *Kamasinski.*

00283326

A190/II/9



- សំណុំឯកសារ ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមមានបញ្ជីពិពណ៌នាអំពីឯកសារភស្តុតាង គាំទ្រដល់ព្រឹត្តការណ៍ ឬឧក្រិដ្ឋកម្មជាក់លាក់ ដែលបានចោទប្រកាន់។
- ឧបសម្ព័ន្ធ គ នៃសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមមានបញ្ជីនៃឯកសារទាំងអស់ ដែលជាផ្នែកមួយនៃសំណុំរឿង នៅពេលដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ។ ឧបសម្ព័ន្ធនេះ អមមកជាមួយនូវសេចក្តីពិពណ៌នាអំពីខ្លឹមសារនៃឯកសារនីមួយៗ។
- បន្ទាប់ពីបើកកិច្ចស៊ើបសួរ ឯកសារភស្តុតាងស្ទើរតែទាំងអស់ ដែលបង្កើតដោយសហចៅក្រមស៊ើបអង្កេត រួមមានភស្តុតាងជាឯកសារ និងកំណត់ហេតុនៃការសួរយកចម្លើយ (ជាភាសាខ្មែរ និង/ឬ ភាសាបារាំង)។ និង
- ដីកា និងសេចក្តីសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ រួមទាំងសេចក្តីសន្និដ្ឋានរបស់ភាគី ចំពោះបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ។

៣៨. ក្នុងចំណោមឯកសារទាំងឡាយ ដែលសហព្រះរាជអាជ្ញាចអង្គុលយោងពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្ទាល់របស់ជនត្រូវចោទ, មានតែឯកសារមួយចំនួនតិចប៉ុណ្ណោះដែលមិនមានជាភាសាខ្មែរ ឬ ភាសាអង់គ្លេស។[២៦]

៣៩. ដោយសារភាសាបារាំងមិនមែនជាភាសាមួយក្នុងចំណោមភាសាការងារទាំងពីរ ដែលជនត្រូវចោទ និងក្រុមការពារក្តីរបស់គាត់ បានជ្រើសរើស, សហមេធាវីការពារក្តីទទួលស្គាល់ថា

[២៦] ក្នុងចំណោមឯកសារដែលយកស្រង់នៅក្នុងលេខយោង ៣៦២ ដល់ ៤០៥ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលលើកឡើងអំពីទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់ជនត្រូវចោទ, មានឯកសារចំនួនតែ ៧ ច្បាប់ ប៉ុណ្ណោះដែលមិនមានជាភាសាខ្មែរ ឬភាសាអង់គ្លេសនៅក្នុងដំណាក់ការនេះ។ ឯកសារ ទាំង ៧ ច្បាប់ នេះ សរុបមានចំនួន ១៦ ទំព័រ ប្រសិនបើដកសៀវភៅចំណងជើង *"J'ai cru aux Khmer Rouges"* (២៧២ ទំព័រ) ចេញ។

00283327



ជនត្រូវចោទ ដែលធ្លាប់បានសិក្សានៅប្រទេសបារាំង "និយាយ និងយល់ភាសាបារាំង ក្នុងកម្រិតមួយជាក់លាក់។"[២៧]

៤០. ជនត្រូវចោទ មានមេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិមួយរូប ជាតំណាងរបស់ខ្លួន អនុលោមតាមសិទ្ធិ ដូចមានចែងនៅក្នុងវិធាន ២២ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញា បានសន្និដ្ឋានថា សហមេធាវីការពារក្តីជាតិរបស់ជនត្រូវចោទ យល់ភាសាខ្មែរ និងភាសាអង់គ្លេស ហើយក្រុមការពារក្តីរបស់ជនត្រូវចោទ ក៏រួមមានមេធាវីកម្ពុជាមួយរូប និងប្រតិភូមួយរូប ដែលចេះទាំងភាសាខ្មែរ និងភាសាអង់គ្លេស[២៨] ហើយមានមេធាវីអង់គ្លេសមួយរូបទៀតផងដែរ។

៤១. បន្ថែមលើក្រុមការងារច្បាប់របស់ខ្លួន ជនត្រូវចោទត្រូវបានគេអនុញ្ញាត "ឱ្យមានជំនួយពីអ្នកបកប្រែម្នាក់ ដែលបំពេញការងារពេញម៉ោង និងមិនគិតថ្លៃ (ចំពោះភាសាការងារជាផ្លូវការចំនួនពីរ តាមការចង្អុលបញ្ជាក់របស់ក្រុមការពារក្តី) ដើម្បីធានាថា ជនត្រូវចោទ និងក្រុមការពារក្តី អាចទទួលបានការបកប្រែឯកសារជាក់លាក់មួយចំនួនតាមតម្រូវការ, ដើម្បីវាយតម្លៃលើតម្រូវការបកប្រែរបស់ក្រុមការពារក្តី ក្នុងការបញ្ជូនមក[ផ្នែកគ្រប់គ្រងតុលាការ] និងដើម្បីជួយដល់ការសហការគ្នារបស់ក្រុមនេះ ជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ។"[២៩] ក្នុងករណីនេះ គេកត់សម្គាល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់ថា ការផ្តល់អ្នកបកប្រែផ្ទាល់មាត់មួយរូបដល់ចុងចោទ គឺជាយន្តការជំនួសគ្រប់គ្រាន់ចំពោះការផ្តល់ការបកប្រែលើឯកសារជាក់លាក់មួយចំនួន។[៣០]

---

[២៧] សំណើឆ្លើយតបរបស់លោក អៀង សារី ចំពោះសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ A190/II/8 ("សំណើឆ្លើយតប") វាក្យខណ្ឌទី ១១។

[២៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា វាក្យខណ្ឌទី ៣៨។

[២៩] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ង (៣)។

[៣០] *Kamasinski*, paras 80-81, 85; *Muhimana*, para. 30; *Lubanga*, p. 7.

៤២. ជនត្រូវចោទ ត្រូវបានគេអនុញ្ញាតឱ្យបង្ហាញឯកសារជាក់លាក់ដើម្បីស្នើសុំការបកប្រែសម្រាប់ខ្លួន ផងដែរ។[៣១]

៤៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានសម្រេចថា ភស្តុតាងដោះបន្ទុក ត្រូវផ្តល់ជូនចុងចោទជាភាសាមួយ ដែលគាត់យល់។ ការធ្វើដូច្នេះ គឺដើម្បីឱ្យចុងចោទអាចរៀបចំការការពារខ្លួនបាន។[៣២] អង្គបុរេជំនុំជម្រះពិចារណាឃើញថា ក្រុមការពារក្តីស្ថិតក្នុងជំហរមួយយ៉ាងសមស្របក្នុងការបង្ហាញនូវឯកសារផ្សេងៗ ដែលអាចជាឯកសារដោះបន្ទុក ហើយបន្ទាប់មកស្នើសុំការបកប្រែឯកសារជាក់លាក់ទាំងនោះ តាមអំណាចនៃដីកាស្តីពីការបកប្រែ។

៤៤. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិនានារបស់ជនត្រូវចោទ ដូចមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង មិនត្រូវបានគេរំលោភឡើយ។ ដីកាសម្រេចស្តីពីការបកប្រែ គឺធ្វើឡើងដោយស្របតាមបទដ្ឋានអន្តរជាតិ ចំពោះសិទ្ធិបកប្រែទាំងនេះ។ ការផ្តល់អ្នកបកប្រែមួយរូបសម្រាប់ក្រុមមេធាវីការពារក្តីដែលប្រើច្រើនភាសា គឺដើម្បីធានាថា តម្រូវការចាំបាច់ទាំងអស់ផ្នែកភាសា បានបំពេញសមស្របនៅក្នុងដំណាក់ការនេះនៅចំពោះមុខ អ.វ.ត.ក។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន២១ នៃវិធានផ្ទៃក្នុង មិនមានអានុភាពចាប់បង្ខំឱ្យធ្វើការបកស្រាយវិធានផ្ទៃក្នុង ក្នុងវិធីមួយដែលនាំដល់ការប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍ចំពោះ ដីកាសម្រេចស្តីពីការបកប្រែនេះឡើយ។

---

[៣១] ដីកាស្តីពីការបកប្រែ ទំព័រទី ៧។

[៣២] *Ljubicic*, p. 3; *Prosecutor v. Prlic*, IT-04-74-PT, "Order for the Translation of Documents", Pre-Trial Chamber, 17 January 2006, p. 2; *Prosecutor v. Seselj*, IT-03-67-PT, "Decision on Form of Disclosure", Trial Chamber I, 4 July 2006, para. 15; *Muhimana*, para. 22.



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00283329

A190/II/9

០០២/១៨-០៩-២០០៧-អវតក/កសចស (អបជ១២)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ:**

**មិនទទួលយកបណ្តឹងឧទ្ធរណ៍នេះ។**

**ភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING **នំយ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**